ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៤/១៤-០១-១៣

**សាលដីកា**
លេខ ១០ ក្រ៧ឃ ចុះ
ថ្ងៃទី ១២-០២-២០១៤

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៦-០២-១៤ ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ៥៤ ចុះថ្ងៃទី ១៤-០១-២០១៣ រវាង ៖

-ជនជាប់ចោទឈ្មោះ

[redacted] **អះម៉ាត់** ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើត សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted]រ៉ ម្តាយឈ្មោះ [redacted]រ៉ នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល ០១ឆ្នាំ ពីបទលួច (ឃុំខ្លួន)។

**ត្រូវជាប់ចោទពីបទ** ៖ លួច "អក់ខ្សែក" ស្ថិតក្នុងលក្ខខណ្ឌមិនរាងចាល ក្នុងបទមជ្ឈឹម ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យទួលប្រាសាទសែនសុខ ផ្លូវលេខ ១០-១៩ ក្រុម៦ ភូមិសំណាង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧-០៤-២០១២ តាមបញ្ញត្តិមាត្រា ៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះគ្មានលេខ [redacted]





Scanned with CamScanner

## ឯរឿងហេតុមានដូចតទៅ

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៧-៤-២០១២ ឈ្មោះ [redacted] សារុំ បានបញ្ជាក់ថា ខ្លួនជិះម៉ូតូចេញពីផ្សារសែនសុខ លុះជិតមកដល់ផ្លូវហាណូយ ក្នុងភូមិសំរោងថ្មី ស្រាប់តែឃើញជនល្មើសម្នាក់ជិះម៉ូតូម៉ាក យ៉ាម៉ាហា ពណ៌ខ្មៅ បានជិះមកទន្ទឹមខ្លួន ហើយលូកដៃឆក់ខ្សែកៈប្លាទីនរបស់ខ្លួនទម្ងន់៣ជី ហើយជិះម៉ូតូឆ្ពោះមកទិសខាងត្បូងបាត់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៧៧"ឃ" ចុះថ្ងៃទី ២៥-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសម្រេចដូចខាងក្រោមៈ

១-ផ្តន្ទាទោសលើឈ្មោះ [redacted] អះម៉ាត់ ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់០២"ពីរ"ឆ្នាំ បូកបន្ថែមចំនួន ០១"មួយ"ឆ្នាំទៀត ចំពោះទោសគុកដែលនៅសល់បានព្យួរទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ១៧"ខ" ចុះថ្ងៃទី ១៩-០២-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ គឺទោសគុកសរុបចំនួន០៣"បី"ឆ្នាំ។

ពីបទអំពើលួច ហើយស្ថិតក្នុងលក្ខខ័ណ្ឌនៃការមិនរាងចាលក្នុងបទមជ្ឈឹម បន្ទាប់ពីផ្តន្ទាទោសក្នុងបទមជ្ឈឹម ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យទួលប្រាសាទសែនសុខ ផ្លូវលេខ១០១៩ ក្រុម៦ ភូមិសំណាង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧-០៤-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣,៣៥៦,៨៣,៨៤,៨៨ និងមាត្រា ៩១ នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុចាប់យក គឺម៉ូតូម៉ាក YAMAHA XT ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AX-៦០៣៧ ដែលមានលេខម៉ាស៊ីន G 340E014950 និងលេខតួ D611 J006665 ប្រគល់ឱ្យម្ចាស់ដើមវិញ។

តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណ: នៅថ្ងៃទី ១២-១០-២០១២ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណ: នៅថ្ងៃទី ២៥-១០-២០១២។

-បានឃើញឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦-១១-២០១២ របស់ឈ្មោះ [redacted] **អះម៉ាត់** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៧"ឃ" ចុះថ្ងៃទី ២៥-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញរបាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២៣-០៤-២០១៣។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ៣០-០៥-២០១៣ ។

## នាពេលសវនាការសាលាឧទ្ធរណ៍

ចៅក្រមអានរបាយការណ៍រឿង

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted] សារុំ

-ឈ្មោះ [redacted] អះម៉ាត់ បានឆ្លើយថា ខ្លួនពិតជាបានប្រព្រឹត្តអំពើឆក់តែម្នាក់ឯងមែន រីឯជនរងគ្រោះមិនបានដួលម៉ូតូទេ។ ខ្លួនប្តឹងឧទ្ធរណ៍នេះដោយមិនសុខចិត្តផ្តន្ទាទោសខ្លួនពីរឆ្នាំហើយ មកបូកថែមមួយឆ្នាំទៀត ម៉្យាងទៀតទោសខ្លួនមួយឆ្នាំបានអនុវត្តនៅក្នុងពន្ធនាគាររួចហើយៗ ចេញមកវិញប្រព្រឹត្តបទល្មើសទៀតគេចាប់បាន។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយបន្ធូបន្ថយទោសដល់រូបខ្លួន។ ៣



Scanned with CamScanner

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

-ពិតមែនតែជនជាប់ចោទមានសំណុំរឿងមុនធ្លាប់ផ្តន្ទាទោស តែសុំក្រុមប្រឹក្សាពិចារណាតាមការសុំបន្ធូបន្ថយទោស ដោយសារជនជាប់ចោទបានទទួលស្គាល់កំហុស។

-មេធាវី [redacted] សុផង់ ការពារសិទ្ធិឱ្យឈ្មោះ [redacted] អះម៉ាត់ បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលក្នុងពេលសវនាការ កូនក្តីខ្លួនបានទទួលសារភាពពីទោសកំហុសរបស់គាត់។ យោងតាមសាលក្រមលេខ ៧៧"ឃ" ចុះថ្ងៃទី ២៥-១០-២០១២ បានសម្រេចផ្តន្ទាទោសកូនក្តីខ្លួនដាក់ពន្ធនាគារចំនួន ០២ឆ្នាំ ដោយដាក់ទោសពន្ធនាគារ០១ឆ្នាំ និងទោសព្យួរ០១ឆ្នាំ ហើយបានយកទោសព្យួរសំណុំរឿងមុន០១ឆ្នាំ មកបូកសំណុំរឿងពេលនេះសរុបទៅឡើងទៅចំនួន០៣ឆ្នាំ បើពិនិត្យទៅលើមាត្រា ១១០ ចំពោះទោសព្យួរ កូនក្តីខ្លួនក៏បានទទួលបានសិទ្ធិមិនដកហូតទោសព្យួរ, តាមមាត្រា ១០៦, ១០៧ ក្រមព្រហ្មទណ្ឌ ចំពោះទោស០២ឆ្នាំ ក៏អាចមានទោសព្យួរបានដែរ និងឆ្លងតាមការសារភាពរបស់កូនក្តីខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចឱ្យកូនក្តីខ្លួនទទួលបានមិនដកហូតទោសព្យួរពីលើកមុន ដូច្នេះបញ្ជាក់ឱ្យឃើញថាមានទោស០២ឆ្នាំគត់ចំពោះទោសថ្មី ហើយចំពោះទោសថ្មី០២ឆ្នាំនេះសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចតាមមាត្រា ១០៦, ១០៧ នៃក្រមព្រហ្មទណ្ឌ ឱ្យមានការព្យួរទោស០១ឆ្នាំថែមទៀត ហើយ០១ឆ្នាំពីលើកមុនសុំរក្សានៅដដែល។

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦-១១-២០១២ របស់ជនជាប់ចោទឈ្មោះ រី អះម៉ាត់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៧"ឃ" ចុះថ្ងៃទី ២៥-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទឈ្មោះ [redacted] អះម៉ាត់ បានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនគ្រប់ដំណាក់កាល ហើយចម្លើយសារភាពនេះមានលក្ខណៈស៊ីសង្វាក់ នឹងចម្លើយរបស់ជនរងគ្រោះ គប្បីតុលាការពិចារណា។

៣-អំពើ និងសកម្មភាពរបស់ជនជាប់ចោទរូបនេះមិនបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរទេ ម្យ៉ាងទៀតដើមបណ្តឹងរដ្ឋប្បវេណីក៏ពុំទាមទារសំណងជម្ងឺចិត្តអ្វីទៀតដែរ។

៤-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ រី អះម៉ាត់ ពីបទលួច ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យទួលប្រាសាទសែនសុខ ផ្លូវលេខ ១០១៩ ក្រុម៦ ភូមិសំណាង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧-០៤-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមបញ្ញត្តិមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៥-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានទទួលសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួន និងសន្យាសុំកែប្រែខ្លួនឱ្យទៅជាពលរដ្ឋល្អក្នុងសង្គមវិញ ទោះបីជាជនជាប់ចោទធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងរួចក៏ដោយ គប្បីសភាព្រហ្មទណ្ឌពិចារណាអំពីស្ថានសំរាលដល់ជនជាប់ចោទរូបនេះតាមច្បាប់។

៦-ជនជាប់ចោទបានសារភាពនូវកំហុសរបស់ខ្លួន,ហើយជនជាប់ចោទមានកំរិតវប្បធម៌ទាបខ្វះការពិចារណាដិតដល់, ជនជាប់ចោទរូបនេះបានជាប់ឃុំឃាំងកន្លងមកមានការភ្ញាក់រឭកច្រើន,

ដូច្នេះសភាព្រហ្មទណ្ឌពិចារណាអំពីស្ថានបន្ធូបន្ថយទោសដល់ជនជាប់ចោទរូបនេះ តាមមាត្រា ៩៣,៩៤ នៃក្រមព្រហ្មទណ្ឌ។

៧-សាលក្រមព្រហ្មទណ្ឌលេខ ៧៧"ឃ" ចុះថ្ងៃទី ២៥-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១ ស្តីពីទណ្ឌកម្មពន្ធនាគារគួរបន្ថយមកត្រឹមចំនួន០២ឆ្នាំវិញ។ ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល។

ហេតុដូច្នេះ

**<u>វិនិច្ឆ័យសេចក្តី</u>**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦-១១-២០១២ របស់ជនជាប់ឈ្មោះ វី អះម៉ាត់ ទុកជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៧"ឃ" ចុះថ្ងៃទី ២៥-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការលើកលែងតែចំណុចទី១ ស្តីពីទណ្ឌកម្មពន្ធនាគារត្រូវបន្ថយមកត្រឹមចំនួន០២ឆ្នាំ វិញ។

-ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល។

៣-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ១២-០២-២០១៤ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងជនជាប់ចោទ។

-បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

| | |
| --- | --- |
| បានឃើញ | សាលាឧទ្ធរណ៍ថ្ងៃទី ៤៥ ខែ ០៣ ឆ្នាំ ២០១៤ |
| **ប្រធានសាលាឧទ្ធរណ៍** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |